クメール語

# កញ្ចប់ស្វាគមន៍ អាយ៉ាសិ

## សៀវភៅមគ្គុទេសក៍អំពីការរស់នៅ
## សម្រាប់ពលរដ្ឋជាជនបរទេស

# あやせウェルカムパック

## 外国人市民のための生活ガイド



## មាតិកា


**1. ពេលមានអាសន្ន 1**

1. នៅពេលដែលជួបគ្រោះថ្នាក់ឬបទល្មើស ទូរស័ព្ទទៅកាន់លេខ«110» 1
2. នៅពេលដែលមានជំងឺបន្ទាន់ឬរងរបួសធ្ងន់ធ្ងរ ទូរស័ព្ទទៅកាន់លេខ «119» ..... 1
3. នៅពេលដែលមានអគ្គីភ័យ ទូរស័ព្ទទៅកាន់លេខ«119» ..... 3
4. នៅពេលដែលឧបករណ៍ព្រមានអគ្គិភ័យសម្រាប់ផ្ទះរោទិ៍ ..... 3

**2. ជំងឺ / របួស 5**

1. ទៅមន្ទីរពេទ្យ ..... 5
2. ការបកប្រែនៅមន្ទីរពេទ្យ (សេវាកម្មនិយាយឆ្លើយឆ្លង3ភាគីផ្នែកវេជ្ជសាស្ត្រនៃក្រុងអាយ៉ាសិ) ..... 5

**3. សេវាកម្មបកប្រែនៃសាលាក្រុង 7**

1. មជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ ..... 7
2. ការបកប្រែនៅសាលាក្រុង ..... 7

**4. ការរស់នៅ 9**

1. របៀបដាក់សំរាម ..... 9
2. សូមចូលរួមសមាគមមូលដ្ឋាន ..... 11
3. ច្បាប់និងសុជីវធម៌អំពីការរស់នៅ ..... 13
4. ការបង់ពន្ធ ..... 15
5. ការពិគ្រោះអំពីលក្ខណៈសម្បត្តិស្នាក់នៅជាដើម ..... 17

**5. ការការពារគ្រោះមហន្តរាយ 19**

1. សូមត្រៀមសម្រាប់គ្រោះមហន្តរាយ ..... 19
2. ព័ត៌មានស្តីពីគ្រោះមហន្តរាយនិងការភៀសខ្លួន ..... 19
3. នៅពេលដែលរញ្ជួយដីកើតឡើង ..... 21
4. នៅពេលដែលខ្យល់ព្យុះមកដល់ឬមានភ្លៀងធ្លាក់ខ្លាំង ..... 23

**6. ការសិក្សាភាសាជប៉ុន 25**

1. ការពិគ្រោះអំពីការសិក្សាភាសាជប៉ុន ..... 25

**7. ព័ត៌មានជាច្រើនភាសានៃសាលាក្រុង 25**

1. ទស្សនាវដ្តីព័ត៌មានជាច្រើនភាសា «Ayase Today» ..... 25
2. «ការផ្សាយជាសារធារណៈ Ayase» ជាច្រើនភាសា ..... 25


## 目次


**1　緊急のとき　2**

1　事故や犯罪にあったら「１１０」に電話・・・・・・・・2
2　急病やひどいケガをしたら「１１９」に電話・・・・・2
3　火事が起きたら「１１９」に電話・・・・・・・・・・4
4　住宅用火災警報器が鳴ったら・・・・・・・・・・・・・4

**2　病気・ケガ　6**

1　病院に行く・・・・・・・・・・・・・・・・・・・・・・6
2　病院での通訳　（綾瀬市の医療用３者通話サービス）・・6

**3　市役所の通訳サービス　8**

1　外国語通訳コールセンター・・・・・・・・・・・・・・8
2　市役所での通訳・・・・・・・・・・・・・・・・・・・8

**4　くらし　10**

1　ごみの出し方・・・・・・・・・・・・・・・・・・・ 10
2　自治会に入りましょう・・・・・・・・・・・・・・・ 12
3　生活のルールとマナー・・・・・・・・・・・・・・・ 14
4　納税・・・・・・・・・・・・・・・・・・・・・・・ 16
5　在留資格などの相談・・・・・・・・・・・・・・・・ 18

**5　防災　20**

1　災害に備えよう・・・・・・・・・・・・・・・・・・ 20
2　災害の情報や避難・・・・・・・・・・・・・・・・・ 20
3　地震が起きたら・・・・・・・・・・・・・・・・・・ 22
4　台風や大雨がきたら・・・・・・・・・・・・・・・・ 24

**6　日本語学習　26**

1　日本語の学習の相談・・・・・・・・・・・・・・・・ 26

**7　市役所の多言語情報　26**

1　多言語情報誌「あやせトゥデイ」・・・・・・・・・・ 26
2　多言語版「広報あやせ」・・・・・・・・・・・・・・ 26

## 1. ពេលមានអាសន្ន

### 1-1. នៅពេលដែលជួបគ្រោះថ្នាក់ឬបទល្មើស ទូរស័ព្ទទៅកាន់លេខ«110»

នៅពេលដែលបង្កគ្រោះថ្នាក់ចរាចរណ៍ឬជួបគ្រោះថ្នាក់ចរាចរណ៍
ទូរស័ព្ទទៅលេខ«110»។
នៅពេលដែលជួបឬឃើញឧប្បត្តិហេតុឬបទល្មើស ក៏ទូរស័ព្ទដែរ។(24ម៉ោង)
ប៉ូលិសនឹងទៅភ្លាមៗ។
នៅពេលដែលមានអ្នករងរបួស ទូរស័ព្ទទៅលេខ«119»ដែរ។

របៀបទូរស័ព្ទទៅលេខ«110» (និយាយភាសាបរទេសក៏បានដែរ)



(1) ចុចលេខ«110»។
(2) ប្រាប់អំពីពេលណា នៅទីណា មានអ្វីកើតឡើង។
(3) ប្រាប់ឈ្មោះ។
(4) បិទទូរស័ព្ទ។
(5) រង់ចាំនៅកន្លែងដែលមានសុវត្ថភាព រហូតដល់ប៉ូលិសមកដល់។

សូមកុំភ័យ ហើយប្រាប់មួយៗនិងឲ្យបានច្បាស់ អំពី«ពេលណា» «នៅទីណា» «មានអ្វីកើតឡើង» និង «ឈ្មោះរបស់ខ្លួនឯង»។

នៅពេលដែលមានគ្រោះថ្នាក់ទោះជាគិតថាគ្មានរបួសក៏ដោយ អាចនឹងមានករណីដែលថ្ងៃក្រោយទើបដឹងថាមានរបួស។ នៅពេលដែលជួបគ្រោះថ្នាក់ ត្រូវទៅមន្ទីរពេទ្យភ្លាមៗ។

### 1-2 នៅពេលដែលមានជំងឺបន្ទាន់ឬរងរបួសធ្ងន់ធ្ងរ ទូរស័ព្ទទៅកាន់លេខ«119»

នៅពេលមានជំងឺបន្ទាន់ឬរងរបួសធ្ងន់ធ្ងរ ទូរស័ព្ទទៅលេខ«119»។
(24ម៉ោង)
រថយន្តសង្គ្រោះបន្ទាន់នឹងទៅភ្លាម។

របៀបទូរស័ព្ទទៅលេខ«119» (និយាយភាសាបរទេសក៏បានដែរ)



(1) ចុចលេខ«119»។
(2) និយាយថា «kyūkyū desu» (សង្គ្រោះបន្ទាន់)។
(3) ប្រាប់អាសយដ្ឋានដែលចង់ឲ្យរថយន្តសង្គ្រោះបន្ទាន់មក។
(4) ប្រាប់អំពីស្ថានភាពនៃរបួសឬជំងឺ។
(5) ប្រាប់ឈ្មោះ។
(6) បិទទូរស័ព្ទ។
(7) ពេលឮស៊ីរ៉ែនរថយន្តសង្គ្រោះបន្ទាន់ ចេញទៅទទួលដើម្បីណែនាំផ្លូវ។

សូមកុំភ័យ ហើយប្រាប់មួយៗនិងឲ្យបានច្បាស់ អំពី«ទីតាំងដែលចង់ឲ្យរថយន្តសង្គ្រោះបន្ទាន់មក»និង «ឈ្មោះរបស់ខ្លួនឯង»។

- ករណីមិនមែនរបួសធ្ងន់ធ្ងរឬជំងឺបន្ទាន់ ដូចជា«ដោយសារស្រួលប្រើ» «ដោយសារថ្នាំដែលបានទទួលនៅមន្ទីរពេទ្យអស់ហើយ» «ដោយសារមិនដឹងត្រូវទៅមន្ទីរពេទ្យមួយណា» សូមទៅមន្ទីរពេទ្យដោយខ្លួនឯង។ ⇒ទំព័រ6
- ការបញ្ជូនទៅមន្ទីរពេទ្យគឺឥតគិតថ្លៃ តែថ្លៃព្យាបាលនៅមន្ទីរពេទ្យជាបន្ទុកខ្លួនឯង។ សូមរៀបចំប័ណ្ណធានារ៉ាប់រងនិងលុយដែលត្រូវការ។





## 1　緊急のとき

### 1-1　事故や犯罪にあったら「１１０」に電話

交通事故を起こしたり、交通事故にあったりしたときは
「１１０」に電話します。
事件や犯罪にあったり、見たときも電話します。〈24 時間〉
すぐに警察が向かいます。
ケガをした人がいるときは「１１９」にも電話します。

「１１０」に電話をかける方法〈外国語も通じます〉



① 「１１０」を押します。
② いつ、どこで、なにが起きたか伝えます。
③ 名前を伝えます。
④ 電話を切ります。
⑤ 警察が来るまで安全な場所で待ちます。

あわてないで、ゆっくり、はっきりと「いつ」「どこで」「なにが起きたか」「自分の名前」を伝えてください。

事故のときは、ケガをしていないと思っても後でケガが分かるときがあります。交通事故にあったら、一度病院に行きましょう。

### 1-2　急病やひどいケガをしたら「１１９」に電話

ひどいケガや急病になったら「１１９」に電話します。〈24 時間〉
すぐに救急車が向かいます。

「１１９」に電話をかける方法〈外国語も通じます〉



① 「１１９」を押します。
② 「kyūkyū desu」（救急です。）と言います。
③ 救急車に来てほしい住所を伝えます。
④ ケガや病気の症状を伝えます。
⑤ 名前を伝えます。
⑥ 電話を切ります。
⑦ 救急車のサイレンが聞こえたら道案内のために迎えに出ます。

あわてないで、ゆっくり、はっきりと「救急車に来てほしい場所」「自分の名前」を伝えてください。

・「便利だから」「病院でもらった薬がなくなった」「どの病院に行けばよいか分からない」などひどいケガや急病でない場合は、自分で病院に行きましょう。⇒６ページ
・病院までの搬送は無料ですが、病院での治療費は自己負担です。健康保険証や必要なお金を用意してください。

## 1. ពេលមានអាសន្ន

### 1-3. **នៅពេលដែលមានអគ្គីភ័យ ទូរស័ព្ទទៅកាន់លេខ «119»**

នៅពេលដែលមានអគ្គីភ័យ ទូរស័ព្ទទៅលេខ«**119**»។(24ម៉ោង)
រថយន្តសង្គ្រោះបន្ទាន់នឹងទៅភ្លាម។

របៀបទូរស័ព្ទទៅលេខ«119» (និយាយភាសាបរទេសក៏បានដែរ)
(1) ចុចលេខ«**119**»។
(2) និយាយថា «kaji desu» (អគ្គិភ័យ)។
(3) ប្រាប់ទីតាំងដែលមានអគ្គិភ័យ។
(4) ប្រាប់ឈ្មោះ។
(5) បិទទូរស័ព្ទ។



សូមកុំភ័យ ហើយប្រាប់មួយៗនិងឲ្យបានច្បាស់ អំពី«ទីតាំងដែលមានអគ្គិភ័យ»និង«ឈ្មោះរបស់ខ្លួនឯង»។

### 1-4 នៅពេលដែលឧបករណ៍ព្រមានអគ្គិភ័យសម្រាប់ផ្ទះរោទិ៍

អ្នកអាចអានខិតប័ណ្ណតាមរយៈQRកូដខាងស្តាំ។

- មានភាសា ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ ភាសាចិន ហាន់ហ្គឹល





## 1　緊急のとき

### 1-3　火事が起きたら「１１９」に電話

火事がおきたら「**１１９**」に電話します。〈24 時間〉
すぐに消防車が向かいます。

「１１９」に電話をかける方法〈外国語も通じます〉
①「**１１９**」を押します。
②「kaji desu」（火事です。）と言います。
③ 火事の場所を伝えます。
④ 名前を伝えます。
⑤ 電話を切ります。



あわてないで、ゆっくり、はっきりと
「火事の場所」「自分の名前」を伝えてください。

### 1-4　住宅用火災警報器が鳴ったら

右のＱＲコードからパンフレットが読めます。

・対応言語　英語、ベトナム語、ポルトガル語、スペイン語、中国語、韓国語

ជំងឺ / របួស

## 2. ជំងឺ / របួស

### 2-1. **ទៅមន្ទីរពេទ្យ**



មន្ទីរពេទ្យដែលទទួលពិគ្រោះប្រែប្រួលទៅតាមប្រភេទនៃជំងឺនិងរបួស។ ពេលទៅមន្ទីរពេទ្យត្រូវការប័ណ្ណធានារ៉ាប់រង ប័ណ្ណស្នាក់នៅ និងលុយ។ អ្នកដែលគ្មានប័ណ្ណធានារ៉ាប់រងត្រូវបង់លុយដោយខ្លួនឯងទាំងស្រុង។ អ្នកមិនត្រូវឲ្យគេខ្ចីឬខ្ចីប័ណ្ណធានារ៉ាប់រងឡើយ។

ក្នុងករណីរងរបួសធ្ងន់ធ្ងរឬមានជំងឺបន្ទាន់ ទូរស័ព្ទទៅលេខ«119»ភ្លាម។ (24ម៉ោង) ⇒ទំព័រទី1

### 2-2. **ការបកប្រែនៅមន្ទីរពេទ្យ (សេវាកម្មនិយាយឆ្លើយឆ្លង3ភាគីផ្នែកវេជ្ជសាស្ត្រនៃក្រុងអាយ៉ាសិ)**

នៅកន្លែង(1) (2) អ្នកអាចប្រើសេវាកម្មបកប្រែតាមទូរទស្សន៍(ថាប្លេត)បាន។

- ភាសា　ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាចិន ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក ហាន់ហ្គីល ភាសាថៃជាដើម

(1) ការពិគ្រោះអំពីសុខភាព
- ផ្នែកជំរុញការធ្វើឲ្យមានសុខភាពល្អក្រុងអាយ៉ាសិ (នៅក្នុងអគារ ហុកេនហ៊ីគីសិុប្លាហ្សា 4-7-10 ហ៊ីកាយ៉ាណាកា)

(2) មន្ទីរពេទ្យ
- មន្ទីរពេទ្យអាយ៉ាសិកូ◌េសប្បូអ៊ិន (1-4-16 ហ៊ីកាយ៉ាណាកា)
- គ្លីនិកអាយ៉ាសិគ្យូជីសីស៊ីន្ទរ៉ូចុ (នៅក្នុងអគារហុកេនហ៊ីគុសិុប្លាហ្សា)

អំពីអ្វីដែលអ្នកមិនយល់ សូមសាកសួរទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ (**0467-70-5682**)។ (អាចនិយាយជាភាសាបរទេសបាន)



病気・ケガ

## 2　病気・ケガ

### 2−1　病院に行く



病気やケガの種類によって、受診する病院が変わります。病院に行くときは、保険証、在留カード、お金がいります。保険証がない人は、お金を全部自分で払います。保険証は他の人に貸しても借りてもいけません。

もしもひどいケガをしたときや急病の場合はすぐ「１１９」に電話します。〈24 時間〉⇒２ページ

### 2−2　病院での通訳（綾瀬市の医療用３者通話サービス）

①②の場所では、テレビ通訳（タブレット）が利用できます。

・対応言語　英語、ベトナム語、ポルトガル語、中国語、スペイン語、タガログ語、韓国語、タイ語など

①健康相談
・綾瀬市健康づくり推進課（深谷中 4−7−10 保健福祉プラザ内）

②病院
・綾瀬厚生病院（深谷中 1−4−16）
・綾瀬休日診療所（保健福祉プラザ内）

分からないことは、外国語通訳コールセンター（０４６７−７０−５６８２）で聞いてください。〈外国語で話せます〉

សេវាកម្មបកប្រែនៃសាលាក្រុង

## 3. សេវាកម្មបកប្រែនៃសាលាក្រុង

### 3-1. **មជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ**

អ្នកបកប្រែ(អ្នកទទួលទូរស័ព្ទ)និ៎ងតភ្ជាប់ជាមួយនឹងផ្នែកដែលទទួលបន្ទុកនៅសាលាក្រុង ហើយអ្នកអាចនិយាយដោយផ្ទាល់តាមរយៈអ្នកបកប្រែបាន។

- លេខទូរស័ព្ទ **0467-70-5682**
- ភាសា ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ ភាសាចិន ភាសាតាហ្គាឡុក ហាន់ហ្គីល ភាសាថៃ
- ម៉ោងបើកដំណើរការ ថ្ងៃធម្មតា ម៉ោង8:30នាទី-ម៉ោង17 (លើកលែងថ្ងៃឈប់សម្រាកបុណ្យជាតិ)

របៀបទូរស័ព្ទទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ
(1) ចុចលេខ**0467-70-5682**។
(2) ប្រាប់អំពីភាសារបស់អ្នក។
(3) អ្នកបកប្រែភាសានោះនឹងឆ្លើយឆ្លងតាមទូរស័ព្ទ។
(4) អ្នក អ្នកបកប្រែនិងបុគ្គលិកសាលាក្រុងទាំង3នាក់អាចនិយាយឆ្លើយឆ្លងបាន។

ឧទាហរណ៍បើមានករណីដូចខាងក្រោម សូមទូរស័ព្ទទៅ។
«មានសំបុត្រផ្ញើមកពីសាលាក្រុង តែខ្ញុំមិនយល់ខ្លឹមសារនោះទេ»
«ខ្ញុំចង់ដឹងបែបបទដែលត្រូវធ្វើ ដោយសារកើតកូន»
«ខ្ញុំចង់ដឹងអំពីការចាក់វ៉ាក់សាំងនិងសាលាសម្រាប់កូនរបស់ខ្ញុំ»
«ខ្ញុំចង់ដឹងអំពីធានារ៉ាប់រងសុខភាពពលរដ្ឋ»ជាដើម

### 3-2. **ការបកប្រែនៅសាលាក្រុង** (អគារធំ៖ 550 ហាយ៉ាកាវ៉ា ក្រុងអាយ៉ាសិ)

➢ នៅបញ្ជរទទួលភ្ញៀវនៃសាលាក្រុង អ្នកអាចប្រើសេវាកម្មបកប្រែតាមទូរទស្សន៍បាន។
- ភាសា ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាចិន ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក ហាន់ហ្គីល ភាសាថៃ
- ម៉ោងបើកដំណើរការ ថ្ងៃធម្មតា ម៉ោង8:30នាទី-ម៉ោង17 (លើកលែងថ្ងៃឈប់សម្រាកបុណ្យជាតិ)

➢ អ្នកបកប្រែរង់ចាំនៅបញ្ជរទទួលភ្ញៀវ នៅថ្ងៃកំណត់រៀងរាល់ខែ។
- ភាសា 2ដងក្នុងមួយខែ ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ
  1ដងក្នុងមួយខែ ភាសាអង់គ្លេស ភាសាវៀតណាម
- អំពីថ្ងៃដែលអ្នកបកប្រែរង់ចាំ សូមសាកសួរទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ (**0467-70-5682**)។ (អាចនិយាយជាភាសាបរទេសបាន)

របៀបប្រើសេវាកម្មបកប្រែតាមទូរទស្សន៍នៅបញ្ជរទទួលភ្ញៀវនៃសាលាក្រុង
(1) ទៅកាន់បញ្ជរទទួលភ្ញៀវលេខ1«ផ្នែកជំរុញសកម្មភាពពលរដ្ឋ»នៅជាន់ទី2នៃសាលាក្រុងអាយ៉ាសិ។
(2) ប្រាប់អំពីភាសារបស់អ្នក។
(3) អ្នកបកប្រែភាសានោះនឹងឆ្លើយឆ្លងដោយសេវាកម្មបកប្រែតាមទូរទស្សន៍(ថាប្លេត)។
(4) អ្នក អ្នកបកប្រែនិងបុគ្គលិកសាលាក្រុងទាំង3នាក់អាចនិយាយឆ្លើយឆ្លងបាន។



市役所の通訳サービス

## 3　市役所の通訳サービス

### 3-1　外国語通訳コールセンター

通訳者（オペレーター）が市役所の担当部署へつなぎ、そのまま通訳者を交えて通話ができます。

・電話番号　**０４６７-７０-５６８２**

・対応言語　英語、ベトナム語、ポルトガル語、スペイン語、中国語、タガログ語、韓国語、タイ語

・対応時間　平日　８時３０分～１７時（祝日除く）

外国語通訳コールセンターに電話をかける方法
① **０４６７-７０-５６８２** を押します。
② あなたの言語を伝えます。
③ その言語の通訳者が電話にでます。
④ あなたと通訳者と市職員との３人で話せます。

たとえば、こんなときに電話してください。
『市役所から手紙が届いたが内容が分からない』
『子どもが生まれたら必要な手続きを知りたい』
『子どもの予防接種のことや、学校のことを知りたい』
『国民健康保険のことを知りたい』　など

### 3-2　市役所での通訳（本庁舎：綾瀬市早川５５０）

➢ 市役所窓口では、テレビ通訳が利用できます。

・対応言語　英語、ベトナム語、ポルトガル語、中国語、スペイン語、タガログ語、韓国語、タイ語
・対応時間　平日　８時３０分～１７時（祝日除く）

➢ 毎月決まった日に、窓口に通訳者もいます。
・対応言語　月２回　ポルトガル語、スペイン語
　　　　　　月１回　英語、ベトナム語
・通訳者がいる日は、外国語通訳コールセンター（０４６７-７０-５６８２）で聞いてください。〈外国語で話せます〉

市役所窓口でテレビ通訳を使う方法
① 綾瀬市役所の２階１番窓口「市民活動推進課」に行きます。
② あなたの言語を伝えます。
③ テレビ通訳（タブレット）でその言語の通訳者がでます。
④ あなたと通訳者と市職員との３人で話せます。

## 4. ការរស់នៅ

### 4-1. **របៀបដាក់សំរាម**

ចំពោះសំរាមចេញពីផ្ទះ សូមដាក់នៅម៉ោងនិងថ្ងៃកំណត់ដោយក្រុង ទៅកន្លែងកំណត់។
សំរាមមានប្រភេទ ហើយត្រូវបានកំណត់នូវថ្ងៃដាក់និងរបៀបដាក់តាមប្រភេទសំរាម។
**គេមិនប្រមូលយកសំរាមដែលបានដាក់ដោយមិនគោរពច្បាប់។**

ចំពោះច្បាប់អំពីរបៀបដាក់សំរាមជាដើម សូមអាន**«សៀវភៅមគ្គុទេសក៍អំពីរបៀបបែងចែក/ដាក់ធនធាននិងសំរាម»**។

- យើងបកប្រែ**«សៀវភៅមគ្គុទេសក៍អំពីរបៀបបែងចែក/ដាក់ធនធាននិងសំរាម»**
  ទៅជាភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាឡាវ ភាសាចិន ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក ហាន់ហ្គឹល ភាសាថៃ។
- សូមដាក់សំរាមពីម៉ោង7ដល់ម៉ោង8:30នាទីព្រឹកនៅថ្ងៃកំណត់។
- ចំពោះថ្ងៃដែលដាក់សំរាមនិងកន្លែងដែលដាក់សំរាម ត្រូវបានកំណត់តាមតំបន់ដែលអ្នករស់នៅ។ សូមអាន**«សៀវភៅមគ្គុទេសក៍អំពីរបៀបបែងចែក/ដាក់ធនធាននិងសំរាម»**។
- ចំពោះសំរាមធំដូចជាគ្រឿងសង្ហារិមជាដើម សូមប្រើការប្រមូលតាមផ្ទះដោយដាក់ពាក្យសុំ ឬយកមកឯរីសាយយលផ្លាហ្សា។
- អំពីអ្វីដែលអ្នកមិនយល់ សូមសាកសួរទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ(**0467-70-5682**)។ (អាចនិយាយជាភាសាបរទេសបាន)

**សូមគូសរង្វង់○នៅលើថ្ងៃដែលដាក់សំរាមចេញពីផ្ទះខ្លួនឯង។**

| ថ្ងៃ | ថ្ងៃច័ន្ទ | ថ្ងៃអង្គារ | ថ្ងៃពុធ | ថ្ងៃព្រហស្បតិ៍ | ថ្ងៃសុក្ក | ថ្ងៃសៅរ៍ |
|---|---|---|---|---|---|---|
| សំរាមដុតឆេះ<br>(សំណល់អាហារ បាយជាដើម) | | | | | | |
| ធនធាន<br>(កំប៉ុងដែក ដប ដបប្លាស្ទិច ក្រដាសជាដើម) | | | | | | |
| ប្លាស្ទិច<br>មានសញ្ញានេះ→ | | | | | | |





## 4　くらし

### 4-1 ごみの出し方

家庭のごみは、市で決められた日時に、決められた場所へ出しましょう。
ごみには種類があり、種類ごとに出す曜日や出し方が決まっています。
**ルールを守らずに出されたごみは収集されません。**

ごみの出し方などのルールは**「資源とごみの分け方・出し方ガイド」**を読んでください。

・**「資源とごみの分け方・出し方ガイド」**は英語、ベトナム語、ポルトガル語、ラオス語、中国語、スペイン語、タガログ語、韓国語、タイ語に翻訳しています。
・ごみは、決められた曜日の朝７時から８時３０分までに出してください。
・ごみを出す曜日やごみを出す場所は、住んでいる地域ごとに決まっています。**「資源とごみの分け方・出し方ガイド」**を読んでください。
・家具などの粗大ごみは、申込みによる戸別収集かリサイクルプラザに持ち込んでください。
・分からないことは外国語通訳コールセンター（０４６７−７０−５６８２）で聞いてください。〈外国語で話せます〉

**自分の家のごみを出す曜日に　○を書きましょう。**

| 曜日 | 月曜日 | 火曜日 | 水曜日 | 木曜日 | 金曜日 | 土曜日 |
|---|---|---|---|---|---|---|
| 可燃ごみ<br>（調理くず，残飯など） | | | | | | |
| 資源ごみ<br>（缶，瓶，ペットボトル，紙など） | | | | | | |
| プラスチック<br>このマークが目印→ | | | | | | |

## 4. ការរស់នៅ

### 4-2. សូមចូលរួមសមាគមមូលដ្ឋាន

គឺជាអង្គភាពពលរដ្ឋសម្រាប់អ្នកដែលរស់នៅក្នុងសហគមន៍នាំគ្នាធ្វើសកម្មភាព។ ការចូលជាសមាជិកឬមិនចូលគឺជាសិទ្ធិសេរីភាពរបស់ពួកគេ តែសូមឲ្យតម្លៃទៅលើទំនាក់ទំនងជាមួយមនុស្សក្នុងសហគមន៍ជានិច្ច ដើម្បីអាចជួយគ្នាទៅវិញទៅមកនៅក្នុងករណីមហន្តរាយធម្មជាតិកើតឡើងឬនៅពេលជួបការពិបាកក្នុងការរស់នៅ។

**សមាគមមូលដ្ឋានធ្វើសកម្មភាពដូចតទៅនេះ!**

◆ការផ្តល់ព័ត៌មាន (ប្រាប់ព័ត៌មានក្នុងតំបន់តាមរយៈក្តារជូនព័ត៌មានជាដើម)
◆ការប្រាស្រ័យទាក់ទងជាមួយអ្នកជិតខាង (ពិធីបុណ្យរដូវក្តៅជាដើម)
◆ត្រៀមសម្រាប់គ្រោះមហន្តរាយ (ការហ្វឹកហាត់ការពារគ្រោះមហន្តរាយជាដើម)
◆ការពារសុវត្ថិភាពក្នុងតំបន់ (សកម្មភាពទាក់ទងនឹងសុវត្ថិភាពចរាចរណ៍ឬការការពារបទល្មើសជាដើម)
◆សកម្មភាពសម្អាតក្នុងតំបន់ (ការគ្រប់គ្រងនិងការបោសសម្អាតកន្លែងប្រមូលសំរាមជាដើម)

របៀបចូលជាសមាជិកសមាគមមូលដ្ឋាន
(1) ទូរស័ព្ទទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ(**0467-70-5682**) ឬក៏ទៅកាន់បញ្ជរទទួលភ្ញៀវលេខ1 «ផ្នែកជំរុញសកម្មភាពពលរដ្ឋ» នៅជាន់ទី2នៃសាលាក្រុងអាយ៉ាសិ។
(2) ពួកយើងនឹងប្រាប់ព័ត៌មានទំនាក់ទំនងរបស់ប្រធានសមាគមមូលដ្ឋាននៅតំបន់របស់អ្នក។
ផ្តល់ជូននូវ «ពាក្យស្នើរសុំចូលជាសមាជិកសមាគមមូលដ្ឋាន»។
(3) សូមដាក់ពាក្យសុំដោយទាក់ទងនឹងប្រធានសមាគមមូលដ្ឋាន។

- អ្នកអាចបោះពុម្ព«ពាក្យស្នើរសុំចូលជាសមាជិកសមាគមមូលដ្ឋាន» ពីគេហទំព័រនៃក្រុង។

ភាសាដែលបានបកប្រែ ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្កាល់ ភាសាឡាវ ភាសាចិន ភាសាអេស្ប៉ាញ ភាសាតាហ្កាឡុក ភាសាខ្មែរ ហាន់ហ្គឺល ភាសាថៃ








## 4　くらし

### 4-2 自治会に入りましょう

同じ地域に住んでいる人たちが集まって活動している住民団体です。入るか入らないかは自由ですが、災害が起こったときや暮らしのなかで困ったときに助け合えるように、日ごろから地域の人とのつながりを大切にしましょう。

**自治会ではこんな活動をしています！**

◆情報の提供（地域の情報を回覧板などで伝えます）
◆住民同士の交流（夏祭りなど）
◆災害に備える（防災訓練など）
◆地域の安全を守る（交通安全や防犯の活動など）
◆地域の美化活動（ごみ収集所の管理や掃除など）

自治会に入る方法
① 外国語通訳コールセンター（０４６７−７０−５６８２）に電話するか綾瀬市役所の２階１番窓口「市民活動推進課」に行きます。
② あなたの地域の自治会長の連絡先をお伝えします。
『自治会の加入申込書』を渡します。
③ 自治会長に連絡して加入申し込みをしてください。

・『自治会加入申込書』は市ホームページから印刷できます。

翻訳言語　英語、ベトナム語、ポルトガル語、ラオス語、中国語、スペイン語、タガログ語、クメール語、韓国語、タイ語




## 4. ការរស់នៅ

### 4-3. ច្បាប់និងសុជីវធម៌អំពីការរស់នៅ

សូមរស់នៅដោយគោរពច្បាប់និងសុជីវធម៌ជប៉ុន។
អំពីអ្វីដែលអ្នកមិនយល់ សូមសាកសួរមនុស្សនៅជុំវិញ។
សូមឲ្យតម្លៃទៅលើទំនាក់ទំនងជាមួយមនុស្សក្នុងសហគមន៍ជានិច្ច ដើម្បីអាចជួយគ្នាទៅវិញទៅមកនៅពេលជួបការពិបាកក្នុងការរស់នៅ។

● សំឡេងរំខាន

- សូមរក្សាភាពស្ងៀមស្ងាត់នៅពេលយប់។ ពេលធ្វើពិធីជប់លៀង សូមប្រុងប្រយ័ត្នកុំឲ្យមានសំឡេងឡូឡារំខាន ដូចអ្នកធ្លាប់នៅប្រទេសខ្លួន។ ថែមទាំងសូមប្រយ័ត្ននឹងទំហំសំឡេងនៅពេលលេងភ្លេង។
- សូមពិភាក្សាជាមួយក្រុមហ៊ុនអចលនទ្រព្យឬម្ចាស់ផ្ទះនៅពេលអ្នកជិតខាងមានសំឡេងឡូឡារំខានដល់អ្នក។

● ច្បាប់ទាក់ទងនឹងលំនៅ

- កន្លែងសម្រាប់ប្រើរួមគ្នានៃខុនដូឬបន្ទប់ជួលដូចជាផ្លូវដើរចូលផ្ទះនិងជណ្តើរគឺជាផ្លូវសម្រាប់រត់គេចខ្លួននៅពេលមានរញ្ជួយដីឬអគ្គិភ័យ។ ដូច្នេះសូមកុំទុកដាក់សំរាម ផើងផ្កា កង់ជាដើមនៅទីនោះ។បើទុកដាក់ អ្នកនឹងត្រូវទីស្នាក់ការពន្លត់អគ្គិភ័យព្រមានដែរ។
- ផ្លូវគឺជាកន្លែងដែលគេប្រើរួមគ្នា។ សូមចតឡាននៅចំណតឡាន។ បើអ្នកចតឡានតាមផ្លូវអ្នកនឹងត្រូវប៉ូលិសព្រមានដែរ។





## 4　くらし

### 4-3 生活のルールとマナー

日本のルールやマナーを守って生活しましょう。
分からないことは、周りの人に聞きましょう。
暮らしのなかで困ったときに助け合えるように、日ごろから地域の人とのつながりを大切にしましょう。

●うるさい音

・夜は静かにしましょう。パーティーのとき自分の国と同じように騒がないように気をつけましょう。また、楽器を演奏するときは、音の大きさに注意しましょう。

・他の部屋の人がうるさいときは、不動産店や家主に相談しましょう。

●すまいのルール

・マンションやアパートの廊下や階段などの共用部分は、地震や火事のときに逃げるための道になります。ごみや植木鉢、自転車などの物を置かないようにしましょう。物を置くと消防署からも注意されます。

・道はみんなのものです。車は駐車場に置きましょう。道路に置くと警察からも注意されます。





## 4. ការរស់នៅ

### 4-4. ការបង់ពន្ធ

ពន្ធដែលគិតតាមប្រាក់ចំណូលរបស់បុគ្គលត្រូវបានបែងចែកដូចជាពន្ធលើនិវាសនជននិងពន្ធសម្រាប់ធានារ៉ាប់រងសុខភាពពលរដ្ឋជាដើម។ ជនបរទេសក៏ត្រូវបង់ពន្ធដូចជនជាតិជប៉ុនដែរ។

### ប្រសិនបើមិនបង់ពន្ធ

- ប្រាក់បន្ថែមសម្រាប់ការបង់ពន្ធយឺតត្រូវបានកំណត់អាស្រ័យទៅតាម រយៈពេលដែលគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃកំណត់រហូតដល់ថ្ងៃដែលអ្នកបង់។
- ប្រសិនបើអ្នកនៅតែមិនបង់ទេ អាចនឹងត្រូវបានពិន័យ ដូចជាការឃុំគ្រងលើទ្រព្យសម្បត្តិជាដើម។
- មានករណីដែលមិនត្រូវបានទទួលស្គាល់ការបន្តរយៈពេលស្នាក់នៅឬមិនត្រូវបានផ្តល់ការអនុញ្ញាតឲ្យចូលសញ្ជាតិជប៉ុនឬស្នាក់នៅ អចិន្ត្រៃយ៍។
- អំពីអ្វីដែលអ្នកមិនយល់ សូមសាកសួរទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ(**0467-70-5682**)។ (អាចនិយាយជាភាសាបរទេសបាន)

● ពន្ធលើនិវាសនជន
- ពន្ធដែលបង់ឲ្យខេត្តនិងក្រុងដោយគិតទៅតាមចំណូលនៃឆ្នាំមុន។
- ទោះបីជាមិនធ្វើការនៅឆ្នាំនេះក៏ដោយ ក៏ត្រូវការបង់ពន្ធ។
- ទោះជាមានសញ្ជាតិណាក៏ដោយ ក៏បង់ឲ្យខេត្តនិងក្រុងដែលអ្នករស់នៅ នៅថ្ងៃទី1ខែ1ជារៀងរាល់ឆ្នាំ។

● ពន្ធសម្រាប់ធានារ៉ាប់រងសុខភាពពលរដ្ឋ
- ពន្ធដែលអ្នកដែលចូលធានារ៉ាប់រងសុខភាពពលរដ្ឋបង់ឲ្យក្រុង។
- ទោះជាគ្មានប្រាក់ចំណូលនៃឆ្នាំមុនក៏ត្រូវការបង់ដែរ។
- ទោះបីជាមិនទៅមន្ទីរពេទ្យក៏ដោយ ក៏ត្រូវការបង់ដែរ។
- អ្នកដែលមានកាតព្វកិច្ចត្រូវបង់ពន្ធគឺជាមេគ្រួសារ។

● ពន្ធលើប្រាក់ចំណូល
- ពន្ធដែលបង់ឲ្យរដ្ឋ ដោយគិតទៅតាមប្រាក់ចំណូលក្នុងឆ្នាំនោះចាប់ពីខែ1រហូតដល់ខែ12។
- ជាធម្មតា ពន្ធលើប្រាក់ចំណូលរបស់បុគ្គលិកត្រូវបានកាត់ទុកពីបៀវត្សជារៀងរាល់ខែដោយស្វ័យប្រវត្តិ។ ចំពោះអ្នករកស៊ីខ្លួនឯងជាដើម សូមប្រកាសពន្ធជូនទៅការិយាល័យពន្ធដារដោយខ្លួនឯង។



## 4　くらし

### 4-4 納税

個人の所得に対する税金は、住民税や国民健康保険税などに分かれます。外国人も日本人と同じく税金を払わなければなりません。

### もし、税金を払わなかったら

・期限の次の日から払う日までの長さによって延滞金がかかります。
・払わないままでいると、財産の差し押さえなどの処分を受ける場合があります。
・在留期間の更新が認められなかったり帰化や永住が認められない場合があります。
・分からないことは外国語通訳コールセンター（０４６７−７０−５６８２）で聞いてください。〈外国語で話せます〉

●住民税
・前年の所得に対して、県と市に払う税金です。
・もし、今年働いていなくても税金を支払う必要があります。
・国籍にかかわらず、毎年１月１日に住んでいる県と市に払います。

●国民健康保険税
・国民健康保険に加入している人が市に払う税金です。
・前年に所得がなくても支払う必要があります。
・もし、病院に行かなくても支払う必要があります。
・納税義務者は、世帯主です。

●所得税
・その年の１月から 12 月までの所得に対して、国に払う税金です。
・勤めている人の所得税は、ふつう毎月の給料から自動的に引かれます。自営業などの人は自分で税務署に申告してください。

## 4. ការរស់នៅ

### 4-5. **ការពិគ្រោះអំពីលក្ខណៈសម្បត្តិស្នាក់នៅជាដើម**

មាន «**មជ្ឈមណ្ឌលព័ត៌មានទូទៅអំពីការស្នាក់នៅរបស់ពលរដ្ឋបរទេស**» នៅការិយាល័យអន្តោប្រវេសន៍(មន្ទីរគ្រប់គ្រងអន្តោប្រវេសន៍)។ នៅពេលមានអ្វីដែលមិនយល់អំពីនីតិវិធីអន្តោប្រវេសន៍(អ្វីដែលអ្នកត្រូវធ្វើនៅពេលមកប្រទេសជប៉ុន)និងស្នាក់នៅ(អ្វីដែលអ្នកត្រូវធ្វើដើម្បីស្នាក់នៅប្រទេសជប៉ុន)ជាដើម គេនឹងឆ្លើយសំណួរ។
អ្នកអាចពិគ្រោះតាមទូរស័ព្ទឬអ៊ីមែលបាន។

### ការពិគ្រោះឬការសាកសួរតាមទូរស័ព្ទ

អ្នកអាចពិគ្រោះដោយទូរស័ព្ទទៅ«**មជ្ឈមណ្ឌលព័ត៌មានទូទៅអំពីការស្នាក់នៅរបស់ពលរដ្ឋបរទេស**»បាន។

- លេខទូរស័ព្ទ **0570-013904**
- ភាសា　ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ ភាសាចិន ភាសាតាហ្គាឡុក ភាសាខ្មែរ ហាន់ហ្គឹល ភាសាថៃ ភាសាឥណ្ឌូណេស៊ី ភាសាសិង្ហលជាដើម
- ម៉ោងបើកដំណើរការ　ថ្ងៃធម្មតា ម៉ោង8:30នាទី-ម៉ោង17:15នាទី (លើកលែងថ្ងៃឈប់សម្រាកបុណ្យជាតិ)

### ការពិគ្រោះឬការសាកសួរតាមអ៊ីមែល

អ្នកអាចពិគ្រោះតាមរយៈអ៊ីមែលទៅកាន់«**មជ្ឈមណ្ឌលព័ត៌មានទូទៅអំពីការស្នាក់នៅរបស់ពលរដ្ឋបរទេស**»បាន។

- អាសយដ្ឋានអ៊ីមែល info-tokyo@i.moj.go.jp
- ភាសា សូមសរសេរជាភាសាជប៉ុនឬភាសាអង់គ្លេស។







## 4　くらし

### 4-5 在留資格などの相談

入管（出入国在留管理局）に『**外国人在留総合インフォメーションセンター**』があります。入国手続（日本に来るときにしなければならないこと）や在留手続（日本にいるためにしなければならないこと）などでわからないことがあるときに、質問に答えます。
電話やメールで相談できます。

### 電話での相談や質問

『外国人在留総合インフォメーションセンター』への電話で相談ができます。

- 電話番号　**０５７０-０１３９０４**
- 対応言語　英語、ベトナム語、ポルトガル語、スペイン語、中国語、タガログ語、クメール語、韓国語、タイ語、インドネシア語、シンハラ語など
- 対応時間　平日　８時３０分～１７時１５分（祝日除く）

### メールでの相談や質問

『外国人在留総合インフォメーションセンター』へメールで相談や質問ができます。

- メールアドレス　info-tokyo@i.moj.go.jp
- 対応言語　日本語か英語で書いてください。



## 5. ការការពារគ្រោះមហន្តរាយ

### 5-1. **សូមត្រៀមសម្រាប់គ្រោះមហន្តរាយ**

ប្រទេសជប៉ុនជាប្រទេសដែលមាន**រញ្ជួយដី**ច្រើនណាស់។
ថែមទាំងមាន**ខ្យល់ព្យុះ**មកប្រហែលពីខែ8ដល់ខែ10។
ខ្យល់ព្យុះនាំឲ្យមានខ្យល់បក់ខ្លាំងនិងភ្លៀងធ្លាក់ខ្លាំង។

សូមបញ្ជាក់ទុកជាមុនអំពីកន្លែងភៀសខ្លួននៅជិតផ្ទះខ្លួនឯងនិងវិធីសាស្ត្រទំនាក់ទំនងជាមួយក្រុមគ្រួសារ។ ហើយសូមត្រៀមទឹកនិងអាហារ។

### 5-2. **ព័ត៌មានស្តីពីគ្រោះមហន្តរាយនិងការភៀសខ្លួន**

- ពេលហានិភ័យនៃគ្រោះមហន្តរាយកើនឡើង នឹងមានការប្រកាសព្រមានឬការបង្គាប់ឲ្យភៀសខ្លួនដោយរដ្ឋឬក្រុង។
- ជូនដំណឹងអំពីការបង្គាប់ឲ្យភៀសខ្លួននិងការបើកកន្លែងភៀសខ្លួនជាដើមតាមរយៈគេហទំព័រនៃក្រុងឬ«អាយ៉ាសិ អាន់ហ្សេន/អាន់សិន មែល»ជាដើម។
- អំពីអ្វីដែលអ្នកមិនយល់ សូមសាកសួរទៅមជ្ឈមណ្ឌលបកប្រែភាសាបរទេសតាមទូរស័ព្ទ(0467-70-5682)។ (អាចនិយាយជាភាសាបរទេសបាន)

◆ សេវាកម្មផ្ញើអ៊ីមែលនៃក្រុងអាយ៉ាសិ«អាយ៉ាសិ អាន់ហ្សេន/អាន់សិន មែល»នឹងផ្ញើព័ត៌មានអំពីគ្រោះមហន្តរាយនិងការបង្គាប់ឲ្យភៀសខ្លួននៅក្នុងក្រុងជាដើមទៅអាសយដ្ឋានអ៊ីមែលដែលពលរដ្ឋចុះឈ្មោះជា ច្រើនភាសា។
របៀបចុះឈ្មោះ«អាយ៉ាសិ អាន់ហ្សេន/អាន់ស៊ិន មែល»
- ផ្ញើអ៊ីមែលទទេទៅអាសយដ្ឋានដើម្បីចុះឈ្មោះពីQRកូដខាងស្តាំ។ សូមចុះឈ្មោះមុននឹងគ្រោះមហន្តរាយកើតឡើង។

- ភាសា　ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ ភាសាចិន ហាន់ហ្គឹល ភាសាជប៉ុនងាយៗជាដើម

◆ នៅវេបសាយសារព័ត៌មានរបស់NHK «NHK WORLD-JAPAN» អ្នកអាចមើលព័ត៌មានថ្មីបំផុតអំពីគ្រោះមហន្តរាយ ជាច្រើនភាសា។

- ភាសា　ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ ភាសាចិន ហាន់ហ្គឹល ភាសាថៃ ភាសាឥណ្ឌូណេស៊ីជាដើម



## 5　防災



### 5-1 災害に備えよう

日本は**地震**がとても多い国です。
また、８月～１０月ころには**台風**がきます。
台風は強い風と大雨をもたらします。

日ごろから、家の近くの避難所や家族との連絡方法を確認しておきましょう。また、水や食べ物を準備しておきましょう。

### 5-2 災害の情報や避難

・災害発生の危険性が高まると、警報や避難指示が国や市から出ます。
・避難指示や避難所の開設などは市のホームページや「あやせ安全・安心メール」などで知らせます。
・分からないことは外国語通訳コールセンター（０４６７-７０-５６８２）で聞いてください。〈外国語で話せます〉

◆綾瀬市のメール配信サービス「あやせ安全・安心メール」は市内の災害情報や避難指示などを、市民が登録したメールアドレスに多言語で配信します。
「あやせ安全・安心メール」の登録方法
・右のＱＲコードから登録用アドレスに空メールを送信します。災害が起きる前に登録しましょう。

・対応言語　英語、ベトナム語、ポルトガル語、スペイン語、中国語、韓国語、やさしい日本語など

◆ＮＨＫのニュースサイト『NHK WORLD-JAPAN』では最新の災害情報を多言語で確認することができます。

・対応言語　英語、ベトナム語、ポルトガル語、スペイン語、中国語、韓国語、タイ語、インドネシア語など

## 5. ការការពារគ្រោះមហន្តរាយ

### 5-3. នៅពេលដែលរញ្ជួយដីកើតឡើង

នៅពេលរញ្ជួយដីកើតឡើង សំខាន់បំផុត សូមធ្វើសកម្មភាពដោយមិនភ័យស្លន់ស្លោ។

(1) នៅពេលញ័ររញ្ជួយ

- លាក់ខ្លួននៅក្រោមតុជាដើមដើម្បីការពារខ្លួន។

(2) នៅពេលបាត់រំញ័រ

- ពន្លត់ភ្លើងនៅចង្ក្រាន។
- បង្កើតផ្លូវរត់ចេញដោយបើកទ្វារឬបង្អួច។

(3) ក្នុងករណីដែលអ្នកមិនអាចរស់នៅផ្ទះខ្លួនឯង ដោយសារវាបានបាក់រលំជាដើម អ្នកនឹងភៀសខ្លួននៅ«កន្លែងភៀសខ្លួនដំបូង» មួយរយៈ។



- កន្លែងភៀសខ្លួនជាសាលកីឡានៃសាលាបឋមសិក្សាឬអនុវិទ្យាល័យជាដើមនៅក្នុងក្រុង។
- **សូមភៀសខ្លួនទៅកន្លែងភៀសខ្លួនដែលនៅជិតផ្ទះខ្លួនឯង។**
- នៅពេលភៀសខ្លួនពីផ្ទះខ្លួនឯង ត្រូវបិទបំពង់ហ្គាសនិងទម្លាក់ឌីសង់ទ័រទុកដើម្បីបង្ការអគ្គិភ័យ។

(4) ពេលដែលលែងមានគ្រោះថ្នាក់ ត្រឡប់ទៅផ្ទះខ្លួនឯងវិញ។

### កន្លែងភៀសខ្លួនដំបូង (សាលកីឡានៃសាលាបឋមសិក្សាឬអនុវិទ្យាល័យជាដើម)

| ឈ្មោះ | អាស័យដ្ឋាន | ឈ្មោះ | អាស័យដ្ឋាន |
|---|---|---|---|
| សាលាបឋមសិក្សាអាយ៉ាសិ | 5-1-1 ហ៊ីកាយ៉ាណាកា | សាលាបឋមសិក្សាហាយ៉ាហ្សូណូ | 420 កូហ្សូណូ |
| សាលាអនុវិទ្យាល័យអាយ៉ាសិ | 2-3-1 ហ៊ីកាយ៉ាមីណាមិ | សាលាអនុវិទ្យាល័យស៊ីរ៉ូយ៉ាម៉ា | 2230 ហាយ៉ាកាវ៉ា |
| សាលាអនុវិទ្យាល័យរ៉ូហុគី | 4-4-1 ហ៊ីកាយ៉ាកាមី | សាលាបឋមសិក្សារ៉ូសេ | 1-2-1 រ៉ូសេ |
| សាលាបឋមសិក្សាគីតាណុដៃ | 9-14-1 អូហ្កាមិ | សាលាអនុវិទ្យាល័យកាសីហ្កាដៃ | 393-1 យ៉ូស៊ីអូកា |
| សាលាអនុវិទ្យាល័យគីតាណុដៃ | 1-2-1 តាតេកាវ៉ា | សាលាបឋមសិក្សាអុជិអៃ | 3-10-1 អូជិអៃគីតា |
| សាលាបឋមសិក្សា | 1-3-1 តេរ៉ាអូដៃ | សាលាបឋមសិក្សារ៉ូណាំង | 1-12-19 កាមិថ្សឹជុដាណាណាកា |
| សាលាបឋមសិក្សាតេរ៉ាអូ | 1-3-1 តេរ៉ាអូមីណាមិ | សាលាបឋមសិក្សាថ្សឹជិដាណា | 6-1-1 កាមិថ្សឹជុដាណាមីណាមិ |
| សាលាបឋមសិក្សារ៉ូហុគី | 3-10-1 តេរ៉ាអូហុនចូ | | |

- កន្លែងភៀសខ្លួនដំបូងត្រូវបានបើកក្រោយពេលគ្រោះមហន្តរាយដូចជារញ្ជួយដីបានកើតឡើង។
- ការភៀសខ្លួនគឺជាការគេចខ្លួនពីកន្លែងមានហនិភ័យនៃគ្រោះមហន្តរាយទៅកន្លែងមានសុវត្ថិភាព។ មិនគ្រាន់តែកន្លែងភៀសខ្លួនប៉ុណ្ណោះទេ តែសូមពិនិត្យមើលជានិច្ចពីកន្លែងដែលអ្នកអាចការពារខ្លួនដូចជាជាន់ទី2នៃផ្ទះខ្លួនឯង ផ្ទះរបស់សាច់ញាតិ/អ្នកស្គាល់គ្នាជាដើម។





## 5　防災

### 5-3 地震が起きたら

地震が起きたら、まずは落ち着いて行動しましょう。

①ゆれているとき

・テーブルの下などに入って身を守ります。

②ゆれが止まったら

・コンロの火を消す。

・扉や窓を開けて、逃げる道をつくります。

③家の倒壊などで、自宅で生活できなくなったら、一時的に「一次避難所」などで避難生活を送ります。



・避難所は市内の小中学校の体育館などです。

・**自宅近くの避難所に避難してください。**

・自宅から避難するときは、火事などを防ぐため、ガスの元栓を閉め、電気のブレーカーを落とします。

④危険がなくなったら、自宅に戻ります。

### 一次避難所（小中学校体育館など）

| 名称 | 所在地 | 名称 | 所在地 |
|---|---|---|---|
| 綾瀬小学校 | 深谷中 5-1-1 | 早園小学校 | 小園 420 |
| 綾瀬中学校 | 深谷南 2-3-1 | 城山中学校 | 早川 2230 |
| 綾北中学校 | 深谷上 4-4-1 | 綾西小学校 | 綾西 1-2-1 |
| 北の台小学校 | 大上 9-14-1 | 春日台中学校 | 吉岡 393-1 |
| 北の台中学校 | 蓼川 1-2-1 | 落合小学校 | 落合北 3-10-1 |
| 天台小学校 | 寺尾台 1-3-1 | 綾南小学校 | 上土棚中 1-12-19 |
| 寺尾小学校 | 寺尾南 1-3-1 | 土棚小学校 | 上土棚南 6-1-1 |
| 綾北小学校 | 寺尾本町 3-10-1 | | |

・一次避難所は地震などの災害の発生後に開設されます。

・避難とは、災害の危険がある所から安全な場所へ逃げることです。避難所だけでなく、自宅の２階や、親族・知人の家など、自分の身を守ることができる場所を日ごろから確認しておきましょう。



## 5. ការការពារគ្រោះមហន្តរាយ

### 5-4. នៅពេលដែលខ្យល់ព្យុះមកដល់ឬមានភ្លៀងធ្លាក់ខ្លាំង

(1) សូមឆែកមើលជានិច្ចនូវព័ត៌មានថ្មីស្ដីពីឧត្តុនិយម តាមទូរទស្សន៍ជាដើម។
- សូមកុំឲ្យចូលទៅជិតទន្លេដែលទឹកកើនឡើងនិងដីចំណោតឡើយ។
- នៅពេលមានភ្លៀងធ្លាក់ខ្លាំងឬខ្យល់ខ្លាំង សូមកុំចេញទៅក្រៅ តែនៅក្នុងអគារមានសុវត្ថភាពដូចជាផ្ទះជាដើម។

(2) ពេលមាន«ការបង្គាប់ឲ្យភៀសខ្លួន»ពីក្រុងឬមានគ្រោះថ្នាក់ដល់ផ្ទះ សូមទៅ«កន្លែងភៀសខ្លួនសម្រាប់ពេលមានគ្រោះមហន្តរាយដោយខ្យល់និងទឹក»ដោយប្រុងប្រយ័ត្ន។
- កន្លែងភៀសខ្លួនសម្រាប់ពេលមានគ្រោះមហន្តរាយដោយខ្យល់និងទឹកជាសាលប្រជុំសមាគមមូលដ្ឋានជាដើមនៅក្នុងក្រុង។
- **សូមភៀសខ្លួនទៅកន្លែងភៀសខ្លួនដែលនៅជិតផ្ទះខ្លួនឯង។**
- នៅពេលភៀសខ្លួនពីផ្ទះខ្លួនឯង ត្រូវបិទបំពង់ហ្គាសនិងទម្លាក់ឌីសង់ទ័រទុក ដើម្បីបង្ការអគ្គិភ័យ។

(3) ពេលដែលលែងមានគ្រោះថ្នាក់ ត្រឡប់ទៅផ្ទះខ្លួនឯងវិញ។



### កន្លែងភៀសខ្លួនសម្រាប់ពេលមានគ្រោះមហន្តរាយដោយខ្យល់និងទឹក (សាលប្រជុំសមាគមមូលដ្ឋានជាដើម)

| ឈ្មោះ | អាស័យដ្ឋាន | ឈ្មោះ | អាស័យដ្ឋាន |
|---|---|---|---|
| សាលប្រជុំសមាគមមូលដ្ឋានអុជិអៃ | 6-1-46 អុជិអៃមីណាមិ | សាលប្រជុំសមាគមមូលដ្ឋានយ៉ូស៊ិអូកា | 2316-10 យ៉ូស៊ិអូកា |
| សាលប្រជុំសមាគមមូលដ្ឋានណាកាមូរ៉ា | 5-23-35 ហ៊ូកាយ៉ាណាកា | សាលប្រជុំសមាគមមូលដ្ឋានរ៉្យូសេ | 2-11-14 រ៉្យូសេ |
| សាលប្រជុំសមាគមមូលដ្ឋានតាតេការ៉ា | 2-11-33 តាតេការ៉ា | សាលប្រជុំសមាគមមូលដ្ឋានកាមិថ្សឹជុដាណា | 4-7-47 កាមិថ្សឹជុដាណាគីតា |
| សាលប្រជុំសមាគមមូលដ្ឋាន អូហ្គាមិ | 5-9-41 អូហ្គាមិ | សាលប្រជុំសុខុមាលភាពមនុស្សចាស់ | 1-3-1 ហ៊ិកាយ៉ាណាកា |
| សាលប្រជុំសមាគមមូលដ្ឋានតេរ៉ាអូមីណាមិ | 2-3-16 តេរ៉ាអូមីណាមិ | សាលកុមារតេរ៉ាអូ | 2-2-1 តេរ៉ាអូគីតា |
| សាលប្រជុំសមាគមមូលដ្ឋានតេរ៉ាអូរ៉្យូហុគី | 2-7-3 តេរ៉ាអូហុនចូ | សាលប្រជុំទំនាក់ទំនងណាន់ប៊ឺ | 1-5-10 កាមិថ្សឹជុដាណាមីណាមិ |
| សាលប្រជុំសមាគមមូលដ្ឋាន តេរ៉ាអូតេនដៃ | 1-12-15 តេរ៉ាអូដៃ | សាលកីឡាចំបាំងសាលាអនុវិទ្យាល័យស៊ីរ៉ូយ៉ាម៉ា | 2230 ហាយ៉ាការ៉ា |
| សាលប្រជុំសមាគមមូលដ្ឋានកូហ្សូណូ | 398-1 កូហ្សូណូ | | |

- គេបើកកន្លែងភៀសខ្លួនសម្រាប់ពេលមានគ្រោះមហន្តរាយដោយខ្យល់និងទឹកមុននឹងគ្រោះមហន្តរាយកើតឡើង ដើម្បីភៀសខ្លួនទុកជាមុន។
- ការភៀសខ្លួនគឺជាការគេចខ្លួនពីកន្លែងមានហនិភ័យនៃគ្រោះមហន្តរាយទៅកន្លែងមានសុវត្ថភាព។ មិនគ្រាន់តែកន្លែងភៀសខ្លួនប៉ុណ្ណោះទេ តែសូមពិនិត្យមើលជានិច្ចពីកន្លែងដែលអាចការពារខ្លួនដូចជាជាន់ទី2នៃផ្ទះខ្លួនឯង ផ្ទះរបស់សាច់ញាតិ/អ្នកស្គាល់គ្នាជាដើម ។





## 5　防災

### 5-4 台風や大雨がきたら

①テレビなどで常に新しい気象情報を確認してください。
- 水の多くなった川やがけには近づかないようにしましょう。
- 雨や風が強いときには、外に出ないで、家などの安全な建物にいましょう。

②市から「避難指示」などが出たときや、家が危険なときは、十分注意して「風水害時避難所」などに行きましょう。
- 風水害時避難所は市内の自治会館などです。
- **自宅近くの避難所に避難してください。**
- 自宅から避難するときは、火事などを防ぐため、ガスの元栓を閉め、電気のブレーカーを落とします。

③危険がなくなったら、自宅に戻ります。



### 風水害時避難所（自治会館など）

| 名称 | 所在地 | 名称 | 所在地 |
|---|---|---|---|
| 落合自治会館 | 落合南 6-1-46 | 吉岡自治会館 | 吉岡 2316-10 |
| 中村自治会館 | 深谷中 5-23-35 | 綾西自治会館 | 綾西 2-11-14 |
| 蓼川自治会館 | 蓼川 2-11-33 | 上土棚自治会館 | 上土棚北 4-7-47 |
| 大上自治会館 | 大上 5-9-41 | 高齢者福祉会館 | 深谷中 1-3-1 |
| 寺尾南自治会館 | 寺尾南 2-3-16 | 寺尾児童館 | 寺尾北 2-2-1 |
| 寺尾綾北自治会館 | 寺尾本町 2-7-3 | 南部ふれあい会館 | 上土棚南 1-5-10 |
| 寺尾天台自治会館 | 寺尾台 1-12-15 | 城山中学校武道場 | 早川 2230 |
| 小園自治会館 | 小園 398-1 | | |

- 風水害時避難所は事前避難のため、災害発生前に開設されます。
- 避難とは、災害の危険がある所から安全な場所へ逃げることです。避難所だけでなく、自宅の２階や、親族・知人の家など、自分の身を守ることができる場所を日ごろから確認しておきましょう。

## 6. ការសិក្សាភាសាជប៉ុន

### 6-1. **ការពិគ្រោះអំពីការសិក្សាភាសាជប៉ុន**

◆ តាមរយៈ«ភាសាជប៉ុននៅកាណាហ្គាវ៉ា»ដែលជាវេបសាយនីតិបុគ្គលដើម្បីមូលនិធិនិងប្រយោជន៍សាធារណៈ មូលនិធិទំនាក់ទំនងអន្តរជាតិកាណាហ្គាវ៉ាគ្រប់គ្រង អាចស្វែងរកថ្នាក់រៀនភាសាជប៉ុននៅក្នុងខេត្តបាន។
ហើយណែនាំអំពីវេបសាយជាដើមដែលមានប្រយោជន៍សម្រាប់ការសិក្សាភាសាជប៉ុនដែរ។

- ភាសាដែលបានបកប្រែ ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាចិន ភាសាអេស្ប៉ាញ ហាន់ហ្គីល

◆ នៅ «មជ្ឈមណ្ឌលគាំទ្រពហុភាសាកាណាហ្គាវ៉ា»នៅខេត្តកាណាហ្គាវ៉ា អ្នកអាចពិគ្រោះអំពីការសិក្សាភាសាជប៉ុនជាដើមតាមទូរស័ព្ទ។

- លេខទូរស័ព្ទ **045-316-2770**
- ភាសា ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាអេស្ប៉ាញ ភាសាចិន ភាសាតាហ្គា ឡូក ហាន់ហ្គីល ភាសាថៃ ភាសាឥណ្ឌូណេស៊ីជាដើម
- ម៉ោងបើកដំណើរការ ថ្ងៃធម្មតា ម៉ោង9-ម៉ោង12 ម៉ោង13-ម៉ោង17:15នាទី (លើកលែងថ្ងៃឈប់សម្រាកបុណ្យជាតិ)



## 7. ព័ត៌មានជាច្រើនភាសានៃសាលាក្រុង

### 7-1. ទស្សនាវដ្តីព័ត៌មានជាច្រើនភាសា **«Ayase Today»**

បោះពុម្ពក្នុងមួយឆ្នាំ3ដង ដើម្បីប្រាប់ពលរដ្ឋជាជនប្រទេសនូវសេចក្តីជូនដំណឹងពីសាលាក្រុងនិងព័ត៌មានអំពីការរស់នៅ។
អ្នកក៏អាចមើលតាមអ៊ីនធើណេតបានដែរ។

- ភាសាដែលបានបកប្រែ ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាឡាវ ភាសាចិន ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក ហាន់ហ្គីល ភាសាថៃ

### 7-2. **«ការផ្សាយជាសារធារណៈ: Ayase»** ជាច្រើនភាសា

អ្នកអាចមើលតាមកំព្យូទ័រ ស្មាតហ្វូននិងថាប្លេតជាដើម នូវ«ការផ្សាយជាសារធារណៈ: Ayase» ដែលក្រុងបោះពុម្ពក្នុងមួយខែ2ដង។

- ភាសាដែលបានបកប្រែ ភាសាអង់គ្លេស ភាសាវៀតណាម ភាសាព័រទុយហ្គាល់ ភាសាឡាវ ភាសាចិន ភាសាអេស្ប៉ាញ ភាសាខ្មែរ ភាសាតាហ្គាឡុក(ភាសាហ្វីលីពីន) ភាសាកូរ៉េ ភាសាថៃ ភាសាសិង្ហល ភាសាតាមិល





## 6　日本語学習

### 6-1 日本語の学習の相談

◆公益財団法人かながわ国際交流財団が運営するサイト「かながわでにほんご」では、県内にある日本語教室を探すことができます。
日本語の勉強に役立つウェブサイトなども紹介しています。

・翻訳言語　英語、ベトナム語、ポルトガル語、中国語、スペイン語、韓国語

◆神奈川県の「多言語支援センターかながわ」では、電話で日本語の学習の相談などができます。

・電話番号　**０４５-３１６-２７７０**

・対応言語　英語、ベトナム語、ポルトガル語、スペイン語、中国語、タガログ語、韓国語、タイ語、インドネシア語など

・対応時間　平日 9 時～12 時、13 時～17 時 15 分（祝日除く）



## 7　市役所の多言語情報

### 7-1 多言語情報誌「あやせトゥデイ」

外国人市民に市役所からのお知らせや暮らしの情報を伝えるため、年３回発行しています。
インターネットでも見ることができます。

・翻訳言語　英語、ベトナム語、ポルトガル語、ラオス語、中国語、スペイン語、タガログ語、韓国語、タイ語

### 7-2 多言語版「広報あやせ」

市が毎月２回発行している「広報あやせ」をパソコン、スマートフォン、タブレットなどで閲覧できます。

・翻訳言語　英語、ベトナム語、ポルトガル語、ラオス語、中国語、スペイン語、クメール語、タガログ語（フィリピン語）、韓国語、タイ語、シンハラ語、タミル語

កញ្ចប់ស្វាគមន៍ អាយ៉ាសិ
សៀវភៅមគ្គុទេសក៍អំពីការរស់នៅ
សម្រាប់ពលរដ្ឋជាជនបរទេស

ចេញផ្សាយនៅ ខែមីនា ឆ្នាំ2023
ចេញផ្សាយដោយ ផ្នែកជំរុញសកម្មភាពពលរដ្ឋក្រុងអាយ៉ាសិ
550 ហាយ៉ាកាវ៉ា ក្រុងអាយ៉ាសិ ខេត្តកាណាហ្គាវ៉ា 252-1192
ទូរស័ព្ទ 0467-70-5657 (ភាសាជប៉ុន)
0467-70-5682 (ភាសាបរទេស)

あやせウェルカムパック
外国人市民のための生活ガイド

発行日 2023年3月
発行 綾瀬市市民活動推進課
〒252ー1192 神奈川県綾瀬市早川550番地
電話 0467ー70ー5657（日本語）
0467ー70ー5682（外国語）